(ជ-១៩៥០-៧-១៩៤៥)
RECIE DU DEPOT LEGAL

គីម-សែត
អតីតគ្រូបង្រៀន

# ទស្សលោកនីតិ

## និងករណីយកិច្ចចំពោះលោកនីតិ

ARCHIVES NATIONALES
COTE B.218
1813-172
1956
ជាតិ
172
159



សម្រាប់សិស្សថ្នាក់

មធ្យមដ្ឋាន – ឧត្តមដ្ឋាន – និងពលរដ្ឋគ្រប់ប្រភេទ

៩.៩.៦ ១១-៣-៥៧

ពួកសៀវភៅសិក្សា

# ឧត្ត
# លោកនីតិ

សម្រាប់គ្រប់ថ្នាក់
នៃបឋមភូមិ សិក្សាបំពេញវិជ្ជា

រៀបរៀងដោយ

**គីម-សែត**

អតីតសិស្សសាលាគរុវិជ្ជាភ្នំពេញ
អតីតគ្រូបង្រៀនមានសញ្ញាប័ត្រគរុកោសល្យសម្បទានៅកម្ពុជាក្រោម

ផ្សាយចេញពី

លេខ ៤១៩ ក
មហាវិថីព្រះបាទមុនី-
វង្ស

បោះពុម្ពលើកទី ១

ព.ស. ២៤៩៩ គីជ.ហួរ គ.ស. ១៩៥៧

# អារម្ភកថា

ក្នុងសៀវភៅនេះ មានមេរៀនគ្រប់គ្រាន់ សម្រាប់ថ្នាក់ទាំងឡាយនៃបឋមភូមិសិក្សាបំពេញវិជ្ជា ព្រមទាំងមានពាក្យពន្យល់ និងពាក្យសួរ ប្រាបតាមវិធីគរុកោសល្យផង ។

ក្រៅពីមេរៀន ដែលមានត្រាទុកក្នុងកម្មវិធីសិក្សាជាផ្លូវការ ខ្ញុំបានបញ្ចូលមេរៀនផ្សេងទៀត ដែលមានប្រយោជន៍សំខាន់ ក្នុងការអប់រំស្មារតីប្រជាជនឲ្យបេះស្នេហាឯករាជ្យ អធិបតេយ្យនិងសេរីភាព ។

សរសេរនៅភ្នំពេញ, ថ្ងៃបុណ្យខួប
រំឭកឯករាជ្យជាតិ, ឆ្នាំ១៩៥៦

**គីម - សែត**

# ជំពូកទី ១

ភូមិ — ឃុំ — មុខងាររបស់មេឃុំ — មនុស្សចំណុះឃុំ ករណីយកិច្ចរបស់មណ្ដាជនក្នុងឃុំ — ស្រុក — ស្រុកទាំងឡាយនៅប្រទេសខ្មែរ — មុខងាររបស់ចៅហ្វាយស្រុក — ខេត្ត — មុខងាររបស់ចៅហ្វាយខេត្ត ។

## — អំពីភូមិ —

មេរៀន — ផ្ទះសំណៅច្រើនរួមគ្នា បានជាភូមិ ។ ភូមិមានធំមានតូច មិនដូចគ្នាទេ ។ តំបន់ដែលមិនសូវមានផ្លូវកាត់គ្នាទៅវិញទៅមក, ប្រជាជនពិបាកប្រកបអាជីវកម្ម ភូមិក្នុងតំបន់នោះ មានផ្ទះសំណៅតិច ។ ឯភូមិណាដែលធំទូលាយ មានផ្លូវកាត់គ្នាទៅវិញទៅមកបានដោយងាយ ប្រជាជនចូលទៅនៅច្រើនកុះករ ។

ពាក្យពន្យល់ –

អាជីវកម្ម = របរចិញ្ចឹមជីវិត ។

ប្រជាជន = មនុស្សដែលរស់នៅក្នុងភូមិ ។

ពាក្យសួរ –

១ – ភូមិអ្នកឈ្មោះអ្វី ?

២ – ដូចម្ដេច ដែលហៅថាភូមិ ?

៣ – ដូចម្ដេច បានជាមានភូមិខ្លះតូច ខ្លះធំ ?

៤ – ភូមិអ្នកមានផ្ទះ ប្រហែលប៉ុន្មានខ្នង ?

៥ – ក្នុងភូមិអ្នក មានជនបរទេស នៅឬទេ ?

## -- អំពីឃុំ --

មេរៀន — ភូមិច្រើនរួមគ្នាមកបានជាឃុំ ។ ឃុំមានតូចមានធំ តាមបញ្ញត្តិកដការរដ្ឋបាល ។ ក្នុងឃុំនីមួយៗមានមន្ត្រីម្នាក់ជាអាណាព្យាបាលលើឃុំ ហៅថាមេ-ឃុំ ។ មន្ទីរដែលមេឃុំធ្វើការ ហៅថា សាលាឃុំ ។ ក្នុងសាលាឃុំ មានស្មៀន , មានជំទប់ ក្រុមជំនុំ ៤ នាក់ ហើយនឹងមេភូមិជួយធ្វើការផង ។

ពាក្យពន្យល់ —

បញ្ញត្តិ = បំរាម , ការចេញបង្គាប់ ។

រដ្ឋបាល = ការគ្រប់គ្រងប្រទេស , ប្រឹក្សាការសម្រាប់ប្រទេស ។

អាណាព្យាបាល = ការមានអំណាចគ្រប់គ្រង , អ្នកគ្រប់គ្រង ។

ពាក្យសួរ –

១ – អ្នកនៅឃុំណា?

២ – ដូចម្ដេច ហៅថាឃុំ ?

៣ – ប្រជាជនក្នុងឃុំ ត្រូវស្ដាប់បង្គាប់អ្នកណា ?

៤ – អ្នកណាខ្លះ នៅធ្វើការក្នុងសាលាឃុំ ?

# - មុខងាររបស់មេឃុំ -

មេរៀន - មេឃុំ ជាមន្ត្រីឃុំ ដែលបានជ្រើសតាំងដោយប្រជាជនក្នុងឃុំ តាមវិធីបោះឆ្នោត ។ មេឃុំត្រូវបំពេញមុខងារដូចតទៅ ៖

១ - ត្រូវការពារទ្រព្យសម្បត្តិរបស់គ្រប់ជំពូកក្នុងឃុំ ។

២ - ត្រូវទទួលពាក្យបណ្ដឹងអំពីបណ្ដាស្រុកក្នុងឃុំ ។

៣ - ត្រូវផ្សះផ្សាគូសត្រូវ ។ បើគូសត្រូវពុំសុខចិត្ត ត្រូវបញ្ជូនពាក្យទៅចៅហ្វាយស្រុក តាមរយៈ ដើម្បីឲ្យតុលាការជំនុំជំរះតាមច្បាប់ ។

៤ - ត្រូវការពារស្រុកឲ្យបានសន្តិសុខ ទីងចំរើនក្នុងការប្រកបមុខរបរជីវកម្ម ។

ពាក្យពន្យល់

មុខងារ = កិច្ចការដែលត្រូវបំពេញ , ភារៈកិច្ច របស់មនុស្សម្នាក់ៗ ឬរបស់ជន មួយក្រុម ។

តាមវយ: = តាមលំដាប់ជាន់ថ្នាក់ ពីទាបទៅខ្ពស់ ឬពីខ្ពស់ចុះមកទាប ។

សន្តិសុខ = ការមិនមានចលាចល, មិនភ្ញាក់ផ្អើល ។ សេចក្ដីសុខក្សេមក្សាន្ត ។

អាជីវកម្ម = របរចិញ្ចឹមជីវិត ។

ពាក្យសួរ. —

១ — អ្នកណាជ្រើសតាំងមេឃុំ ?

២ — បើសិនណា អ្នកបានធ្វើជាមេឃុំ អ្នកនឹងបំពេញ មុខងារដូចម្ដេចខ្លះ ?

៣ — មេឃុំរបស់អ្នកសព្វថ្ងៃនេះ បានបំពេញមុខងារត្រឹមត្រូវតាមច្បាប់ឬទេ ?

៤ — នឹងមានអ្វីប្លែកនៅក្នុងឃុំ បើមេឃុំជាមន្ត្រីទុច្ចរិត ? បើជាមន្ត្រីសុចរិតល្អវិញ ?

## - មនុស្សបំណុះឃុំ -

មេរៀន .- ក្នុងប្រទេសកម្ពុជាយើង មានជនបរទេសអា-ស្រ័យនៅច្រើនណាស់ ៗ ក្នុងភូមិ, ក្នុងឃុំ គេឃើញមានជនជាតិចិន វៀតណាមជាច្រើន ; ខ្លះនៅលាយឡំនឹងខ្មែរ ខ្លះនៅជាក្រុមរបស់គេ ។ ជនទាំងនេះមិនទុកជាប្រជាជនរបស់យើងទេ ក៏ប៉ុន្តែទុកជារាស្ត្រចំណុះឃុំរបស់យើង ពីព្រោះពួកនេះមានទីលំនៅក្នុងរយៈឃុំ ប្រកបការរកស៊ីជាមួយប្រជាជនខ្មែរ ហើយបានបង់ពន្ធជាគ្រប់ជំពូក ជូនរាជការក្នុងឃុំនោះ ។ បណ្ដាជនក្នុងឃុំត្រូវស្គាល់ករណីយកិច្ចរបស់ខ្លួនហើយត្រូវស្រឡាញ់គ្នា រួមកម្លាំងសាមគ្គីគ្នាឲ្យបានរឹងប៉ឹង ៗ

ពាក្យពន្យល់

ជនបរទេស = ជនក្រៅប្រទេស , មនុស្សដែលមាន

ដែលមានជាតិដោយឡែក ៗ

ករណីយកិច្ច = កិច្ចដែលត្រូវប្រព្រឹត្តជាការចាំបាច់ ៗ

មុខងាររបស់មនុស្សម្នាក់ៗឬជនមួយក្រុមៗ

សាមគ្គី = សេចក្ដីព្រមព្រៀងរួមកំលាំងចិត្តកំលាំង

កាយជាមួយគ្នា ៗ

ពាក្យសួរ. —

១ -ក្នុងប្រទេសកម្ពុជា មានបណ្ដាជនចំនួនប៉ុន្មាននាក់ ?

២ – ក្រៅអំពីប្រជាជនខ្មែរ មានជនជាតិអ្វីខ្លះ មករស់នៅលើទឹកដីខ្មែរ ?

៣ – ដូចម្ដេច ហៅថា មនុស្សចំណុះឃុំ ?

៤ – បណ្ដាជនក្នុងឃុំ ត្រូវមានចិត្តដូចម្ដេចនឹងគ្នា ?

## - ករណីយកិច្ច របស់បណ្ដាជន ក្នុងឃុំ -

មេរៀន

បណ្ដាជនក្នុងឃុំ ត្រូវស្គាល់ និងត្រូវបំពេញករ-ណីយកិច្ច របស់ខ្លួន ដូចតទៅ ៖

១ - ត្រូវជួយទំនុកបំរុងរាជការឃុំ នៅពេលដែលជួបប្រទះនឹងការវិបាក ៗ

២ - ត្រូវប្រតិបត្តិតាមច្បាប់បញ្ញត្តិដូចមានខាងក្រោម-នេះ ៖

ក - ) ត្រូវបង់ពន្ធគ្រប់ជំពូក ជូនរាជការ ៗ

ខ - ) កាលណាមានមនុស្សទុច្ចរិត ត្រូវប្ដឹងដល់មេឃុំភ្លាម ៗ

គ - ) បើចង់ទៅនៅទីកន្លែងណាផ្សេងទៀត ត្រូវប្ដឹងមេឃុំ ឲ្យបំណាយឈ្មោះចេញពីបញ្ជីឃុំចាស់ ៗ

ឃ - ) ត្រូវយកកូនទៅបណ្ដុះអុតនឹងចាក់ថ្នាំ ការពារ

ជម្ងឺផ្សេងៗ ។

ង-) កូនអាយុបាន៦ឆ្នាំ ត្រូវបញ្ជូនទៅសាលារៀនកុំខាន ។

ច-) បើរើសបានវត្ថុអ្វីក្តី ឬចាប់បានសត្វពាហនៈក្តី ត្រូវនាំយកទៅភ្នាក់ងារឃុំ យ៉ាងឆាប់ ។

ឆ-) បើមានកូនកើតឬស្លាប់ ឬធ្វើបុណ្យតាមផ្សេងៗ ត្រូវទៅប្តឹងមេឃុំកុំខានឡើយសោះ ។

ពាក្យពន្យល់ :-

ការវិបាក = ការមានអាសន្ន, ការជួបប្រទះនឹងឧបសគ្គ ។

មនុស្សទុច្ចរិត = អ្នកប្រព្រឹត្តអំពើអាក្រក់ ។

ប្រតិបត្តិ = ធ្វើតាម, គោរពតាមបទបញ្ជា ។

ពាក្យសួរ. —

១ — អ្នកនៅឃុំណា ?

២ — ក្នុងឃុំអ្នក មានជនបរទេសអាស្រ័យនៅឬទេ ? គឺជាតិណាខ្លះ ?

៣ — ដូចម្ដេចហៅថាមនុស្សចំណុះឃុំ ?

៤ — មនុស្សចំណុះឃុំ ត្រូវបំពេញករណីយកិច្ចដូចម្ដេចខ្លះ ?

## - អំពីស្រុក -

មេរៀន.-

ឃុំច្រើនរួមគ្នា បានជាស្រុក ។ ក្នុងស្រុកនីមួយ ៗ មានមន្ត្រីភ្នាក់ងារជាចៅហ្វាយស្រុក ជាអ្នកត្រួតត្រា មើលការខុសត្រូវលើស្រុក ។ មន្ទីរដែលចៅហ្វាយស្រុកធ្វើការហៅថាសាលាស្រុក ។ ក្នុងសាលាស្រុក មានបាឡាត់ស្រុក, យោក្បត់ ស្មៀននិងប៉ូលីស ជួយធ្វើការចៅហ្វាយស្រុកផង ។

ពាក្យពន្យល់.-

មន្ត្រី = អ្នកប្រឹក្សា ។

យោក្បត់ = ឋានន្តរៈមន្ត្រីថ្នាក់មួយ ។

ពាក្យសួរ.-

១- ឃុំច្រើនរួមគ្នាមកបានជាអ្វី ?

២- អ្នកណាជាអាណាព្យាបាលលើស្រុក ?

៣ - ក្នុងសាលាស្រុក អ្នកឃើញមន្ត្រីណាខ្លះ?

# – ស្រុកទាំងឡាយនៅប្រទេសខ្មែរ –

មេរៀន .–

ស្រុកមានតូចមានធំ មិនដូចគ្នាទេ តាមបញ្ញត្តិពជការវត្តុផល ។

ស្រុកទាំងឡាយនៅប្រទេសខ្មែរគឺ៖

១ – ស្រុកភ្នំពេញ

២ – ស្រុកពញាឮ

៣ – ស្រុកខ្សាច់កណ្ដាល

៤ – ស្រុកមុខកំពូល

៥ – ស្រុកកៀនស្វាយ

៦ – ស្រុកល្វាឯម

៧ – ស្រុកកណ្ដាលស្ទឹង

៨ – ស្រុកលើកដែក

៩ – ស្រុកស្អាង

១០ — ស្រុកកោះធំ

១១ — ស្រុកកំពង់សៀម

១២ — ស្រុកព្រៃឈរ

១៣ — ស្រុកជើងព្រៃ

១៤ — ស្រុកចំការលើ

១៥ — ស្រុកកោះសូទិន

១៦ — ស្រុកត្បូងឃ្មុំ

១៧ — ស្រុកក្រូចឆ្មារ

១៨ — ស្រុកមេមត់

១៩ — ស្រុកស្ទឹងត្រែង

២០ — ស្រុកស្រែសន្ធរ

២១ — ស្រុកកងមាស

២២ — ស្រុកកំពត

២៣ — ស្រុកព្រៃនប់

២៤ – ស្រុកបន្ទាយមាស

២៥ – ស្រុកកំពង់ត្រាច

២៦ – ស្រុកកំពង់សោម

២៧ – ស្រុកឈូក

២៨ – ស្រុកកោះកុង

២៩ – ស្រុកដំណាប់

៣០ – ស្រុកព្រៃវែង

៣១ – ស្រុកកំចាយមារ

៣២ – ស្រុកពាក់នី

៣៣ – ស្រុកស៊ីធរកណ្ដាល

៣៤ – ស្រុកបាភ្នំ

៣៥ – ស្រុកអាំងបីញ

៣៦ – ស្រុកកំពង់ត្របែក

៣៧ – ស្រុកកញ្ជៀប

៣៨ – ស្រុកបរិបូណ៌

៣៩ – ស្រុកកំពង់លែង

៤០ – ស្រុកកំពង់ត្រឡាច

៤១ – ស្រុករលាប្អៀរ

៤២ – ស្រុកតាំងផ្ដោច

៤៣ – ស្រុកត្រាំង

៤៤ – ស្រុកគិរីវង់

៤៥ – ស្រុកបាទី

៤៦ – ស្រុកសំរោង

៤៧ = ស្រុកព្រៃកប្បាស

៤៨ = ស្រុកត្រាំកក់

៤៩ = ស្រុករំដួល

៥០ = ស្រុកស្វាយទាប

៥១ – ស្រុករមាសហែក

៥២ — ស្រុកកំពង់ស្វាយ
៥៣ — ស្រុកសណ្ដាន់
៥៤ — ស្រុកព្រំទេព
៥៥ — ស្រុកបារាយណ៍
៥៦ — ស្រុកស្ទោង
៥៧ — ស្រុកសន្ទុក
៥៨ — ស្រុកសៀមរាប
៥៩ — ស្រុកពួក
៦០ — ស្រុកសូទ្រនិគម
៦១ — ស្រុកជីក្រែង
៦២ — ស្រុកក្រឡាញ់
៦៣ — ស្រុកសម្បូណ៌
៦៤ — ស្រុកស្រួល
៦៥ — ស្រុកឆ្លូង

៦៦ - ស្រុកសំរោងទង

៦៧ - ស្រុកគងពិសី

៦៨ - ស្រុកថ្ពង

៦៩ - ស្រុកភ្នំស្រួច

៧០ - ស្រុកបាកាន

៧១ - ស្រុកភ្នំក្រវាញ

៧២ - ស្រុកក្រគរ

៧៣ - ស្រុកស្ទឹងត្រែង

៧៤ - ស្រុកវឺនសៃ

៧៥ - ស្រុកសៀមបូក

៧៦ - ស្រុកសៀមប៉ាង

៧៧ - ស្រុកឡុមផាត់

៧៨ - ស្រុកបាត់ជំបង

៧៩ - ស្រុកមោនបុស្សី

៨០ – ស្រុកទឹកផោរ

៨១ – ស្រុកសិរីសោភ័ណ

៨២ – ស្រុកមង្គលបូរី

៨៣ – តំបន់រដ្ឋបាលស្វាយចេក

៨៤ – តំបន់រដ្ឋបាលបាក់ព្រា

៨៥ – តំបន់រដ្ឋបាបេល្វា

ពាក្យសួរ –

១ – នៅប្រទេសខ្មែរ មានស្រុកប៉ុន្មាន ?

២ – ស្រុកទាំងនោះមានវិសាលភាពប៉ុន្មានគ្នា ឬទេ ?

៣ – ស្រុកអ្នក ឈ្មោះស្រុកអ្វី ?

៤ – ស្រុកអ្នកមានឃុំប៉ុន្មាន ?

## – មុខងាររបស់ចៅហ្វាយស្រុក –

មេរៀន .–

ចៅហ្វាយស្រុក ជាមន្ត្រី ជ្រើសតាំង ដោយព្រះរាជរដ្ឋាភិបាល ។

ក្រសួងចៅហ្វាយស្រុក មានដូចតទៅ ៖

១ – ត្រូវធ្វើឲ្យរាស្ត្របានសេចក្ដីសុខ, បំបាត់ចោរ កំណាចចេញពីក្នុងស្រុក ដើម្បីឲ្យបានចំរើន គោគសម្បត្តិដល់ប្រជារាស្ត្រ ។

២ – ត្រូវរៀបចំស្រុកឲ្យបានថ្កុំថ្កើនរុងរឿង ធ្វើផ្លូវ, ធ្វើស្ពាន ជីកព្រែក, ធ្វើឲ្យមានផ្លូវចេញចូលកាន់ គ្នាទៅវិញទៅមក ពីស្រុកមួយទៅស្រុកមួយបាន ដោយងាយ ។

៣ – ត្រូវប្រមូលប្រាក់ពន្ធពីមេឃុំនានា យកទៅដាក់ ឃ្លាំង ឲ្យបានទាន់ពេលវេលា ។

៤– ត្រូវខ្នាតពន្យល់បណ្ដារាស្ត្រក្នុងស្រុក ឲ្យប្រតិបត្តិច្បាប់ស្រុកដោយត្រឹមត្រូវ, ពន្យល់ប្រជារាស្ត្រអំពីក្បួនអនាម័យ អំពីរបៀបរកស៊ី អំពីវិទ្យា-សាស្ត្រ ដើម្បីបំបាត់សេចក្ដីល្ងង់ខ្លៅ និងអប្រីយជំនឿផ្សេងៗ ចោលចេញ ។

ពាក្យពន្យល់

អនាម័យ= ភាពដែលមិនមានជម្ងឺ ។

វិទ្យាសាស្ត្រ= វិជ្ជាស្រាវជ្រាវ រិះរកសេចក្ដីពិតគ្រប់យ៉ាង ។

អប្រីយជំនឿ= ការជឿដោយឥតសមហេតុសមផល ។

ពាក្យសួរ

១ – អ្នកណាជ្រើសតាំងចៅហ្វាយស្រុក ?

២ – បើអ្នកបានធ្វើជាចៅហ្វាយស្រុក អ្នកបំពេញមុខងារដូចម្ដេចខ្លះ ?

៣– បើមានមេឃុំណាមួយ មិនខិតខំទារប្រាក់ពន្ធគ្រប់ជំពូកអំពីរាស្ត្រ តើរូបអ្នកដែលជាចៅហ្វាយស្រុកអ្នកត្រូវធ្វើដូចម្តេច?

## - អំពីខេត្ត -

មេរៀន.-

ស្រុកច្រើនរួមគ្នា កើតបានជាខេត្តៗ ប្រទេសកម្ពុជាមាន ១៤ ខេត្ត គឺ៖

១ - ខេត្តកណ្ដាល

២ - ខេត្តកំពង់ស្ពឺ

៣ - ខេត្តតាកែវ

៤ - ខេត្តកំពត

៥ - ខេត្តព្រៃវែង

៦ - ខេត្តស្វាយរៀង

៧ - ខេត្តកំពង់ចាម

៨ - ខេត្តក្រចេះ

៩ - ខេត្តស្ទឹងត្រែង

១០ - ខេត្តកំពង់ធំ

១១ - ខេត្តកំពង់ឆ្នាំង

១២ - ខេត្តពោធិសាត់

១៣ - ខេត្តសៀមរាប

១៤ - ខេត្តបាត់ដំបង ។

ក្នុងខេត្តនីមួយ ៗ មានមន្ត្រីជាន់ខ្ពស់ម្នាក់ងារជា ចៅហ្វាយខេត្ត មើលត្រួតត្រាការខុសត្រូវ លើចៅហ្វាយស្រុក និងមន្ត្រីឯទៀតនៅក្នុងខេត្ត ។ មន្ទីរដែលមានលោកចៅហ្វាយខេត្តធ្វើការហៅថា សាលាខេត្ត ។

ពាក្យសួរ

១ - ស្រុកច្រើនរួមគ្នា កើតបានជាអ្វី ?

២ - អ្នកនៅក្នុងខេត្តណា ?

៣ - ប្រទេសកម្ពុជា មានខេត្តប៉ុន្មាន ?

៤ – លោកចៅហ្វាយខេត្ត នៅខេត្តអ្នក ឈ្មោះអ្វី ?

៥ – លោកធ្វើការនៅកន្លែងណា ?

## - មុខងាររបស់ចៅហ្វាយខេត្ត -

មេរៀន

ចៅហ្វាយខេត្តជាមន្ត្រីជាន់ខ្ពស់ ជ្រើសតាំងដោយព្រះរាជរដ្ឋាភិបាល ។

ក្រសួងចៅហ្វាយខេត្ត មានដូចតទៅ ៖

១ – ត្រូវប្រមូលប្រាក់ពន្ធ គ្រប់មុខពីចៅហ្វាយស្រុក ។

២ – ត្រូវរៀបចំខេត្តឲ្យបានចុះចើនរុងរឿង ឲ្យបានសន្តិសុខ នឹងចំរើនភោគសម្ប័ទ ។

៣ – ត្រូវទទួលពត៌មានផ្សេងៗ ពីចៅហ្វាយស្រុក ហើយពិនិត្យមើលឲ្យបានត្រឹមត្រូវ រួចបញ្ជូនទៅតាមក្រសួង ។

៤ – ត្រូវទទួលបញ្ជាបញ្ញត្តិអំពីរដ្ឋមន្ត្រី ហើយចាត់ការបង្គាប់ ទៅចៅហ្វាយស្រុកឲ្យប្រតិបត្តិតាម ។

ពាក្យពន្យល់

សន្តិសុខ = ភាពក្សេមក្សាន្ត មិនមានភិតភ័យ ។

ពត៌មាន = ដំណឹង, សេចក្តីរាយការណ៍ផ្សេងៗ ។

វេជ្ជបណ្ឌិត = នាម៉ឺនជាន់ខ្ពស់ខាងរដ្ឋបាលខេត្ត, អ្នកធ្វើនយោបាយ ដឹកនាំប្រទេស ទៅកាន់សេចក្តីចំរើន ។

ប្រតិបត្តិ = ធ្វើតាម ។

ពាក្យសួរ. —

១ — អ្នកណាជ្រើសតាំង ចៅហ្វាយខេត្ត ?

២ — ចៅហ្វាយខេត្ត ខេត្តសៀមរាប ឧនិវខេត្ត បាត់ដំបង មានឈ្មោះជាអ្វី ?

៣ — បើអ្នកបានធ្វើជាចៅហ្វាយខេត្ត អ្នកបំពេញ មុខងារ ដូចម្តេចខ្លះ ?

# — បណ្ដាជននៅប្រទេសខ្មែរ —

មេរៀន .—

នៅប្រទេសខ្មែរ មានបណ្ដាជនប្រហែល ៥ លាននាក់ ហើយក្នុងចំនួននេះ បាន រាប់បញ្ចូលទាំងជនជាតិបរទេសផង ។

## ១ .— ខេត្តស្ទឹងត្រែង

| | |
|---|---|
| ប្រជាជនខ្មែរ | ១២.៨០០ នាក់ |
| ជនជាតិលាវ | ១០.០០០ នាក់ |
| ព្នង | ២១.០០០ នាក់ |
| ចិន | ២.៤០០ នាក់ |
| យួន | ៦០០ នាក់ |
| ភូមា | ២០០ នាក់ |

## ២ ខេត្តក្រចេះ

| | |
|---|---|
| ខ្មែរ | ៥៥.០០០ នាក់ |

| | | |
|---|---|---|
| ព្នង | ១០.០០០ | នាក់ |
| យួន | ៦.០០០ | នាក់ |
| ចាម | ៣.០០០ | នាក់ |
| ចិន | ៣.០០០ | នាក់ |

## ៣.– ខេត្តកំពង់ចាម

| | | |
|---|---|---|
| ខ្មែរ | ៥៤៣.០០០ | នាក់ |
| ចាម | ៣០.០០០ | នាក់ |
| យួន | ១៥.០០០ | នាក់ |
| ចិន | ១៦.០០០ | នាក់ |

## ៤– ខេត្តកំពង់ធំ

| | | |
|---|---|---|
| ខ្មែរ | ២០៤.០០០ | នាក់ |
| គួយ | ៤.៥០០ | នាក់ |
| យួន | ២.០០០ | នាក់ |
| ចិន | ២.០០០ | នាក់ |

## ៥ – ខេត្តកំពង់ឆ្នាំង

| | |
|---|---|
| ខ្មែរ | ១៥០.០០០ នាក់ |
| យួន | ២៤.០០០ នាក់ |
| ចិន | ៤.០០០ នាក់ |
| ចាម | ៣.០០០ នាក់ |

## ៦ – ខេត្តសៀមរាប

| | |
|---|---|
| ខ្មែរ | ២១១.០០០ នាក់ |
| យួន | ២.៣០០ នាក់ |
| ចិន | ១.៥០០ នាក់ |

## ៧ – ខេត្តបាត់ដំបង

| | |
|---|---|
| ខ្មែរ | ៤៤០.០០០ នាក់ |
| យួន | ១៦.០០០ នាក់ |
| ចិន | ១៥.០០០ នាក់ |

## ៨ - ខេត្តពោធិសាត់

ខ្មែរ ១៤៥.០០០ នាក់

យួន ៦.០០០ នាក់

ចិន ៥.០០០ នាក់

លាវ ៣០០ នាក់

## ៩ - ខេត្តព្រៃវែង

ខ្មែរ ៣០០.០០០ នាក់

យួន ៥០.០០០ នាក់

ចិន ៧.០០០ នាក់

## ១០ - ខេត្តស្វាយរៀង

ខ្មែរ ១៩៤.១០០ នាក់

យួន ៣០.០០០ នាក់

ចិន ៤.០០០ នាក់

## ១១ - ខេត្តកណ្ដាល

ខ្មែរ ៥៩០.០០០ នាក់

យួន ១៤៣.០០០ នាក់

ចាម ១០.០០០ នាក់

ចិន ១១៥.០០០ នាក់

## ១២ - ខេត្តកំពង់ស្ពឺ

ខ្មែរ ១៧៥.០០០ នាក់

ចិន ៤.០០០ នាក់

យួន ៥០០ នាក់

## ១៣ - ខេត្តតាកែវ

ខ្មែរ ៣៤៣ ០០០ នាក់

យួន ១៥.០០០ នាក់

ចិន ៦,០០០ នាក់

ចាម ១.០០០ នាក់

## ១៤ ខេត្តកំពត

| | | |
|---|---|---|
| ខ្មែរ | ១៩៥.០០០ | នាក់ |
| ចិន | ២០.០០០ | នាក់ |
| យួន | ៧.០០០ | នាក់ |
| ចាម | ៧.០០០ | នាក់ |
| ស៊ូប | ២០០ | នាក់ |

## ក្រុងភ្នំពេញ

| | | |
|---|---|---|
| ខ្មែរ | ២៦០.០០០ | នាក់ |
| ចិន | ១០០.០០០ | នាក់ |
| យួន | ១១០.០០០ | នាក់ |
| ជាតិអឺរ៉ុប | ៣.៨០១ | នាក់ |

ពាក្យសួរ.–

១– ប្រទេសខ្មែរ មានបណ្ដាជនចំនួនប៉ុន្មាន ?

២– ជាតិបរទេស ដែលពឹងអាស្រ័យលើទឹកដីយើង តាំងទុកជាប្រជាជនយើងឬទេ ?

៣– ជនបរទេសនេះ មានអំណាចបង្កើនយោធាយ ក្នុងប្រទេសយើងឬទេ ?

# ជំពូកទី ២

| |
|---|
| ប្រទេសខ្មែរ – អំពីព្រះមហាក្សត្រិយ៍ – អំពីរដ្ឋសភា – អំពីរបៀបជ្រើសតាំងអ្នកតំណាងរាស្ត្រ – អំពីសភាប្រជារាស្ត្រប្រចាំខេត្ត និងប្រចាំព្រះរាជធានី – អំពីក្រុមប្រឹក្សាព្រះរាជអាណាចក្រ – អំពីរដ្ឋាភិបាល – អំពីគណៈរដ្ឋមន្ត្រី – |

## – ប្រទេសខ្មែរ –

មេរៀន .–

ប្រទេសខ្មែរ ឈ្មោះថា កម្ពុជា ។ កម្ពុជាជារដ្ឋរាជានិយម កាន់លទ្ធិប្រជាធិបតេយ្យមានរដ្ឋធម្មនុញ្ញ តាំងពីឆ្នាំ ១៩៤៧ មក ។ កម្ពុជាជាប្រទេសអព្យាក្រឹត មានឥស្សរភាពនិងអធិបតេយ្យគ្រប់គ្រាន់ បានអនុវត្តនយោបាយ ៥ លក្ខណ៍ការរួមរស់នៅក្នុងសន្តិភាព ។

កម្ពុជា ជាសមាជិកនៃអង្គការសហប្រជាជាតិ (ថ្ងៃ១៤ ធ្នូ ១៩៥៥) ។ របៀបរាជការមានគ្រប់គ្រាន់ ដូចប្រទេសប្រជាធិបតេយ្យដទៃដែរ គឺមានរដ្ឋសភា, ក្រុមប្រឹក្សាព្រះរាជអាណាចក្រ, រដ្ឋាភិបាល ទីផ្នុលាការ ។

ពាក្យពន្យល់ .-

រាជានិយម = ប្រទេសនិយមស្តេច ; ប្រទេសដែលយកស្តេចជាធំបង្អស់ ។

លទ្ធិប្រជាធិបតេយ្យ = អធិបតី នៅលើប្រជារាស្ត្រ ; រាស្ត្រជាធំ ។

រដ្ឋធម្មនុញ្ញ = ច្បាប់សម្រាប់រដ្ឋ, ច្បាប់ដែលអ្នកកំណាន់របស់រាស្ត្របង្កើត ។

អព្យាក្រឹត = នៅកណ្តាល មិនអើតេរកាខ្មែ ឬទៅស្តាំ ។

ឥស្សរភាព = ភាវៈមានអំណាចបរិបូណ៌ (ឯក-
រាជ្យ) ។

អធិបតេយ្យ ឬ អធិបតីភាព = ភាពជាធំក្នុងចំ-
ណោម ។

អនុវត្ត = ធ្វើតាម, យកតម្រាប់តាម ។

វេទិកា = ទីប្រជុំប្រឹក្សាការសម្រាប់ប្រទេស

ពាក្យសួរ

១- កម្ពុជា ជារដ្ឋបែបម្ដេច ?

២- កម្ពុជា បានចូលជាសមាជិកអង្គការសហប្រជា-
ជាតិកាលពីឆ្នាំណា ?

៣- កម្ពុជាអនុវត្តនយោបាយដូចម្ដេច ?

៤- ប្រទេសកម្ពុជាមានរបៀបចាត់ចែងកិច្ចការ យ៉ាង
ណាខ្លះ ?

## - អំពីព្រះមហាក្សត្រិយ៍ -

មេរៀន. -

ព្រះមហាក្សត្រិយ៍ ទ្រង់ជាអគ្គប្រមុខនៃរដ្ឋ, ជាទីគោរពសក្ការៈនរណានឹងល្មើសពុំបាន ។ នីតិ-ភាពនៃព្រះមហាក្សត្រិយ៍ ត្រូវកំណត់តាំងពីព្រះជន្មាយុ ១៨ ព្រះវស្សា ។ ព្រះមហាក្សត្រិយ៍ទ្រង់នូវរាជសិទ្ធិរំលាយរដ្ឋសភាបាន, ទ្រង់ជ្រើសយកនាយករដ្ឋមន្ត្រី, ទ្រង់ជាអធិបតីទីប្រជុំគណៈរដ្ឋមន្ត្រី, ទ្រង់បង្កើតព្រមទាំងព្រះរាជ-ទានឋានន្តរៈស័ក្តិខាងស៊ីវិលនិងខាងទាហាន ។ ទ្រង់នូវរាជសិទ្ធិ លើកលែងទោស និងបន្ធូយទោស; ទ្រង់ជាអគ្គប្រមុខលើកំឡាំងទាហានទាំងឡាយ ។

ព្រះមហាក្សត្រិយ៍ ខ្មែរបច្ចុប្បន្ននេះ ទ្រង់ព្រះ

នាមព្រះសុភម្រឹត ហើយនឹងព្រះមហាក្សត្រិ-
យានី ព្រះនាមព្រះកុសុមនារីរត្ន ។ អគ្គប្រមុខ
រដ្ឋ ទ្រង់គង់នៅក្នុងព្រះបរមរាជវាំងនាក្រុងចតុ-
មុខ ភ្នំពេញ ។

ពាក្យពន្យល់ .—

មហាក្សត្រិយ៍ = ស្ដេចធំ ។

ទីតិកាល = គ្រប់ច្បាប់ ; ភាពជាអ្នកពេញការ ។

រាជសិទ្ធិ = អំណាចរបស់ព្រះរាជា ; អំណាច របស់ស្ដេច ។

ហ៊ានន្តរសក្តិ = ឥរសក្តិ ។

បច្ចុប្បន្ន = សម័យនេះ, ក្នុងគ្រាឥឡូវនេះ ។

ពាក្យសួរ.-

១ - អ្នកណាជាប្រមុខរដ្ឋខ្មែរ ?

២ - ព្រះមហាក្សត្រិយ៍ទ្រង់នូវរាជសិទ្ធិណាខ្លះ ?

៣ - ព្រះមហាក្សត្រិយ៍ និងព្រះមហាក្សត្រិយានីខ្មែរ-

យើង នាបច្ចុប្បន្ននេះ ទ្រង់ព្រះនាមអ្វី ?

★★

# - អំពីរដ្ឋសភា -

មេរៀន ៈ-

រដ្ឋសភាជាអ្នកប្រើអំណាចនីតិបញ្ញត្តិ ។ រដ្ឋសភាមានសិទ្ធិពេញមត់តាំងច្បាប់ ។ សមាជិកទាំងឡាយនៅរដ្ឋសភា ជាអ្នកតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ។ តាមគោលការណ៍ក្នុងចំនួនពលរដ្ឋខ្មែរ ១០.០០០ នាក់ ដែលមានអាយុ ២០ ឆ្នាំឡើងទៅត្រូវមានអ្នកតំណាងមួយរូប ។ អ្នកតំណាងរាស្ត្រត្រូវមានអាយុ ២៥ ឆ្នាំយ៉ាងតិច ហើយនៅក្នុងតំណែងខ្លួន បានត្រឹមតែ ៤ ឆ្នាំទេ ។ ក្នុងសមាជិកភាពនៃរដ្ឋសភា អ្នកតំណាងរាស្ត្រ មិនអាចត្រូវចោទប្រកាន់រកខ្លួន ចាប់ខ្លួនបុំឃាំង ឬយកទៅជំនុំជំរះឡើយ ។ រដ្ឋសភា មានសម័យប្រជុំសាមញ្ញយ៉ាងតិច

២ ដងក្នុងមួយឆ្នាំ ៗ សម័យប្រជុំនីមួយ ៗ មាន
កំណត់យ៉ាងតិចត្រឹម ៣ ខែ ៗ

មន្ទីរវេជ្ជសភា ឋិតនៅក្រុងភ្នំពេញ សព្វ
ថ្ងៃនេះមានសមាជិកទាំងអស់ ៩១ រូប ៗ

ពាក្យពន្យល់ .-

វេជ្ជសភា = ទីប្រឹក្សាការសម្រាប់វេជ្ជ ៗ

អំណាចនីតិបញ្ញត្តិ=អំណាចធ្វើច្បាប់សម្រាប់ប្រជាជនៗ

សាមញ្ញ = ធម្មតា

ពាក្យសួរ -

១– អ្នកតំណាងរាស្ត្រ ចូលទៅប្រជុំឯទីណា ?

២– វេជ្ជសភាមានអំណាចអ្វី ?

៣– បេក្ខជនតំណាងរាស្ត្រ ត្រូវមានអាយុយ៉ាងតិច
ត្រឹមប៉ុន្មានឆ្នាំ ?

៤– គេអាចចាប់ចងឃុំឃាំង អ្នកតំណាងរាស្ត្រ ក្នុង

ពេលដែលនៅជាសមាជិកភាពបានដែរ ឬទេ ?

៥– ក្នុងរដ្ឋសភាខ្មែរសព្វថ្ងៃ មានសមាជិកប៉ុន្មាននាក់ ?

៦– អ្នកតំណាងរាស្ត្រនៅស្រុកអ្នក ឈ្មោះអ្វី ?

៧– អ្នកតំណាងរាស្ត្រនេះ បានចូលទៅកាន់រដ្ឋសភា តាំងពីពេលណា ?

## - អំពីរបៀបជ្រើសតាំងតំណាងរាស្ត្រ -

មេរៀន .-

ការជ្រើសតាំងតំណាងរាស្ត្រ ត្រូវធ្វើដោយវិធីបោះឆ្នោតសម្ងាត់ជាសាកល ។ ក្នុងសម័យបោះឆ្នោតនោះ មានបេក្ខជនជាច្រើន ឈរឈ្មោះឲ្យគេជ្រើសតាំង ។ បុរសនិងស្ត្រីខ្មែរទាំងឡាយមានសិទ្ធិឈរឈ្មោះជាបេក្ខជន និងមានសិទ្ធិបោះឆ្នោតឲ្យបេក្ខជនណាមួយដែលខ្លួនគាប់ចិត្ត ។ អធិបតេយ្យ នៃបណ្ដាជនទាំងឡាយ នឹងអាចប្រព្រឹត្តទៅបាន ដោយសារការជ្រើសតាំងអ្នកតំណាងនេះ ដ្បិតអ្នកតំណាងនេះហើយ ដែលជាអ្នកសម្រេចការផ្សេងៗ និងចាត់ចែងកិច្ចនានាក្នុងការគ្រប់គ្រងប្រទេស ព្រមទាំងជាអ្នកតែងច្បាប់ក្នុងនាមបណ្ដាជនផង ។

ហេតុនេះ ពលរដ្ឋម្នាក់ៗ មានករណីយ-
កិច្ចនឹងជ្រើសតាំងអ្នកតំណាងខ្លួនឲ្យត្រឹមត្រូវ គឺ
ជាជ្រើសតាំង ដោយឥតទាក់ទិននឹងលាភ
ផ្សេង ៗ ។

ត្រូវបោះឆ្នោតឲ្យបេក្ខជន ឬ បេក្ខជនណា
ដែលខ្លួនជឿជាក់ថា មានសម្បទាគ្រប់គ្រាន់
នឹងធ្វើការឲ្យប្រទេសជាតិបាន ។

ពាក្យពន្យល់ .-

បេក្ខជន = អ្នកឈរឈ្មោះប្រឡង ៗ

ពលរដ្ឋ = កំលាំងរបស់ប្រទេស គឺប្រជាជន ។

សម្បទា = សមត្ថភាពអង់អាច, មានចំណេះបរិបូណ៌ ។

ពាក្យសួរ -

១- ការជ្រើសតាំងអ្នកតំណាងរាស្ត្រ ត្រូវធ្វើតាមវិធីណា ?

២- អ្នកណា មានសិទ្ធជ្រើសតាំងអ្នកតំណាងរាស្ត្រ ?

៣- អ្នកដែលឃើញគេបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រឬទេ ?

៤- គេបង់សន្លឹកឆ្នោតនៅកន្លែងណា ?

៥- ការបោះឆ្នោត មានប្រយោជន៍ឬទេ ?

៦- បើអ្នកបានធ្វើជាតំណាងរាស្ត្រ អ្នកមានចិត្តដូចម្តេច ចំពោះរាស្ត្រទាំងឡាយក្នុងមណ្ឌលរបស់អ្នក ?

# អំពីសភាប្រជារាស្ត្រប្រចាំខេត្ត នឹងប្រចាំព្រះរាជធានី

មេរៀន .—

ក្រៅអំពីរដ្ឋសភា ដែលមានទីតាំងនៅឯភ្នំពេញ យើងមានសភាមួយទៀត ហៅថាសភាប្រជារាស្ត្រប្រចាំខេត្តនឹងប្រចាំព្រះរាជធានី ។

សមាជិកនៃសភានេះ ជាអ្នកតំណាងស្រុកនីមួយ ៗ ក្នុងខេត្ត នឹងជាអ្នកតំណាងសង្កាត់នីមួយ ៗ ក្នុងរាជធានី ។

រដ្ឋធម្មនុញ្ញ បង្កើតឲ្យមានសភាប្រជារាស្ត្រនេះ ដើម្បីឲ្យការត្រួតត្រារបស់ប្រជាជន លើរដ្ឋាភិបាល បានជិតជិតទៅទៀត ។

សមាជិកនៃសភាប្រជារាស្ត្រ ត្រូវជ្រើសតាំងតាមវិធីបោះឆ្នោតសាកលដោយចំពោះ ៗ អ្នកដែលមានសិទ្ធិបោះឆ្នោតនោះ គឺពលរដ្ឋខ្មែរទាំង

ពីរគេ ដែលមានអាយុយ៉ាងតិច ២០ ឆ្នាំ ។

សភាប្រជារាស្ត្រ ត្រូវប្រជុំនៅទីប្រជុំខេត្ត ឬនៅរាជធានី ក្នុងមន្ទីរមួយដែលបានរៀបប្រចាំការ ។

សមាជិកសភាប្រជារាស្ត្រ ត្រូវជ្រើសតាំង សម្រាប់ពីរឆ្នាំ ។

សភាប្រជារាស្ត្រ មានភារៈបញ្ចេញមតិ, ជូនយោបល់ ចំពោះការអនុមតិ នៃថវិកាជាតិ ចំពោះបញ្ជីស្រង់ប្រាក់ចំណូល ចំណាយផ្តាច់ឆ្នាំ សេចក្តីព្រាងកិច្ចចងការប្រាក់នៃរដ្ឋាភិបាល ។

ពាក្យពន្យល់ .–

រដ្ឋធម្មនុញ្ញ = ច្បាប់សម្រាប់រដ្ឋ ។

រាជធានី = ទីក្រុងធំដែលមានស្តេចគង់នៅ ។

មតិ = យោបល់ ។

ថវិកា = ប្រាក់ចំណូល និងប្រាក់ចំណាយ ។

ពាក្យសួរ.–

១ – ដទៃពីរដ្ឋសភា នៅស្រុកខ្មែរយើងមានសភាអ្វី· ទៀតទេ ?

២ – សភាប្រជារាស្ត្រ មានប្រយោជន៍អ្វីដល់ជាតិ ឬទេ ?

៣ – សភានេះមានអាណត្តិប៉ុន្មានឆ្នាំ ?

៤ – ស្ត្រី មានសិទ្ធិឈរឈ្មោះជាបេក្ខជនសភាប្រ· ជារាស្ត្របានឬទេ ?

៥ – ទីប្រជុំនៃសភាប្រជារាស្ត្រ នៅឯណា ?

៦ – បើអ្នកបានធ្វើជាសមាជិកសភាប្រជារាស្ត្រ អ្នកនឹងបំពេញមុខការអ្វីខ្លះ ?

# -អំពីក្រុមប្រឹក្សាព្រះរាជអាណាចក្រ-

មេរៀន—

ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ជាសភាមួយធ្វើការអមសភាប្រជាជាតិ ក្នុងកិច្ចបង្កើតច្បាប់សម្រាប់នគរ ។ ក្រុមនេះមានភារៈខាងឲ្យយោបល់ក្នុងការសំរេចច្បាប់នីមួយ ៗ ប៉ុន្តែគ្មានសិទ្ធិបញ្ចេញមតិតាំងច្បាប់ទេ ។ គណៈរដ្ឋមន្ត្រីមិនទទួលខុសត្រូវចំពោះក្រុមប្រឹក្សាព្រះរាជអាណាចក្រឡើយ ។

សមាជិកក្រុមប្រឹក្សាព្រះរាជអាណាចក្រ មាន ២០ រូប ។ សមាជិកខ្លះត្រូវតាត់តាំង ខ្លះត្រូវជ្រើសតាំង ដោយបោះឆ្នោតអសាកល ។ ទីងឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាព្រះរាជអាណាចក្របាន ត្រូវមានអាយុយ៉ាងតិចត្រឹម ៤០ ឆ្នាំ ។

អាណត្តិនៃក្រុមប្រឹក្សាព្រះរាជាណាចក្រ មាន ៤ ឆ្នាំ ដូចសភាប្រជាជាតិដែរ ។

ពាក្យពន្យល់.-

សិទ្ធិ = អំណាច ។

មតិ = យោបល់ ។

អាណត្តិ ៤ ឆ្នាំ = កំណត់ពេល ៤ ឆ្នាំ យ៉ាងដាច់ខាត ។

ពាក្យសួរ.-

១ - ក្រុមណាធ្វើការអមសភាប្រជាជាតិ ?

២ - ក្រុមប្រឹក្សា ព្រះរាជាណាចក្រមានសិទ្ធិបញ្ចេញមតិតាំងច្បាប់ ឬទេ ?

៣ – ហេតុដូចម្តេច បានជាគណៈរដ្ឋមន្ត្រី មិនទទួលខុសត្រូវចំពោះក្រុមប្រឹក្សាព្រះរាជអាណាចក្រ ?

៤ – ទឹងឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាព្រះរាជអាណាចក្រ បុគ្គលម្នាក់ៗ ត្រូវមានអាយុប៉ុន្មាន ?

៥ – អាណត្តិនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ ខុសគ្នាពីសភាប្រជាជាតិ ឬទេ ?

★ ★

## - អំពីរដ្ឋាភិបាល -

មេរៀន .-

រដ្ឋាភិបាល ជាអ្នកកាន់អំណាចនីតិប្រតិបត្តិ គឺជាអ្នកអនុវត្តច្បាប់ ដែលរដ្ឋសភាបានបង្កើត ។

ក្នុងរដ្ឋាភិបាល មាននាយកមួយរូបហៅថា នាយករដ្ឋមន្ត្រី ។ នាយករដ្ឋមន្ត្រីនេះ បានជ្រើសតាំងដោយព្រះមហាក្សត្រិយ៍ ។ នាយករដ្ឋមន្ត្រី រើសមន្ត្រីឯទៀតដោយខ្លួនឯង តែរដ្ឋមន្ត្រីទាំងអស់ អាចចូលកាន់តំណែងបានលុះត្រាតែបានទទួល សេចក្តីទុកចិត្តអំពីរដ្ឋសភាផង ។

គណៈរដ្ឋមន្ត្រីប្រជុំគ្នា រាល់សប្តាហ៍ដើម្បីពាត់វិធានការណ៍ អនុវត្តច្បាប់ ។ គណៈរដ្ឋមន្ត្រី មានអំណាចព្រាងច្បាប់ដែរ ហើយផ្ញើ

ទៅឲ្យរដ្ឋសភាអនុមតិ ។

រដ្ឋមន្ត្រីគ្រប់រូប ទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា

អំពីកិច្ចនយោបាយទូទៅ ។

ពាក្យពន្យល់ .–

និតិប្រតិបត្តិ = ធ្វើតាមច្បាប់បង្គាប់មក ។

អនុវត្តន៍ = ការធ្វើតាម ។

អនុមតិ = យល់ព្រម ។

នយោបាយ = គលល្បិចដឹកនាំប្រទេសជាតិ ។

ពាក្យសួរ.–

១– រដ្ឋាភិបាល កាន់អំណាចអ្វី ?

២– រដ្ឋាភិបាលមានសិទ្ធិព្រាងច្បាប់ឬទេ ?

៣– អ្នកណាជ្រើសតាំងនាយករដ្ឋមន្ត្រី ?

៤– ហេតុដូចម្តេចបានជាគណៈរដ្ឋមន្ត្រី ទទួលខុសត្រូវ

រួមគ្នា ចំពោះរដ្ឋសភា ?

★ ★ ★

## – អំពីគណៈរដ្ឋមន្ត្រី –

មេរៀន .–

គណៈរដ្ឋមន្ត្រីមានសមាជិកយ៉ាងច្រើនត្រឹម ១២ រូប រាប់បញ្ចូលទាំងរដ្ឋលេខាធិការផង ។ រដ្ឋមន្ត្រីមួយរូប ៗ ជានាយកលើក្រសួងនីមួយ ៗ ដូចជា៖

នាយករដ្ឋមន្ត្រី Président du conseil des ministres-

រដ្ឋមន្ត្រីការបរទេស Ministre des affaires étrangères

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ Ministrse de l'intérieur

រដ្ឋមន្ត្រីក្រសួងសាធារណៈសិក្សាធិការ Ministre de l'instruction publique

រដ្ឋមន្ត្រីក្រសួងសាធារណៈសុខាភិបាល Ministre de la santé publique

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ Ministre des finances

រដ្ឋមន្ត្រីក្រសួងការពារជាតិ : Ministre de la défense nationale

រដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ : Ministre de la sécurité nationale

រដ្ឋមន្ត្រីក្រសួងសាធារណៈការ : Ministre des travauœ publics

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ : Ministre de la justice

រដ្ឋមន្ត្រីក្រសួងឃោសនាការជាតិ : Ministre de l'information nationale

រដ្ឋមន្ត្រីក្រសួងកសិកម្ម : Ministre be l'agriculture

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចជាតិ . Ministre de l'économie nationale

ពាក្យសួរ –

១– អ្នកណាជ្រើសតាំងនាយករដ្ឋមន្ត្រី ?

២– អ្នកណារើសយករដ្ឋមន្ត្រីឯទៀតៗ ?

៣– ក្នុងរដ្ឋាភិបាលនីមួយៗ មានរដ្ឋមន្ត្រីជួបគ្នាឬទេ?

៤– អ្នកណាធំជាងគេ ក្នុងក្រសួងសិក្សាធិការ ?

# ជំពូកទី៣

អំពីរបៀបតុលាការ – អំពីអំណាចតុលាការ – ព្រះមហាក្សត្រិយ៍ នឹងតុលាការជាន់ខ្ពស់ – ចៅក្រមនឹងព្រះរាជអាជ្ញា – សាលាលហុ – សាលាដំបូង – សាលាក្រុមទោស – សាលាឧទ្ធរណ៍ – សាលាឧក្រិដ្ឋ – សាលាវិនិច្ឆ័យ – បទប្រព្រឹត្តដែលមានត្រាទុកក្នុងច្បាប់ – តំណែងសក្ដិមន្ត្រីតុលាការ ។

## – អំពីរបៀបតុលាការ –

មេរៀន .–

ក្រុមតុលាការ សំរាប់ជំនុំជំរះកាត់សេចក្ដី, ពិន័យ ឬធ្វើទោសជនណា ដែលប្រព្រឹត្តបទល្មើសនឹងច្បាប់ ឬកើតហេតុទាស់ទែងនឹងគ្នា ។ ក្រុមតុលាការ មានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ (គឺលោកយោមរាជ) ជានាយកត្រួតត្រា ហើយក្រុមនេះមានច្រើនថ្នាក់ទៀតផង ដូចសា សាលហុ –

សាលាដំបូង – សាលាក្រុមចោទ – សាលាឧទ្ធរណ៍ – សាលាឧក្រិដ្ឋ និងសាលាវិនិច្ឆ័យ ។

ពាក្យសួរ .–

១– ក្រុមណាដែលមានការៈ កាត់សេចក្ដីពិន័យធ្វើទោសដល់ជន ដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ ។

២– អ្នកណាជានាយកត្រួតត្រាលើក្រុមតុលាការ ?

៣– ក្រុមតុលាការនៅប្រទេសខ្មែរ មានប៉ុន្មានថ្នាក់?

៤– ចូរបង្ហាញមន្ទីរចាត់ការក្រុមតុលាការ ក្នុងទីប្រជុំខេត្តរបស់អ្នក ។

## - អំពីអំណាចតុលាការ -

មេរៀន. -

អំណាចតុលាការ គឺអំណាចកាត់សេចក្ដីរកខុសរកត្រូវ តាមដោយយុត្តិធម៌ ។

ច្បាប់តុលាការមានត្រាទុកក្នុងច្បាប់ព្រហ្ម-ទណ្ឌ នឹងក្នុងច្បាប់រដ្ឋប្បវេណី ។ នៅពេលកាត់ក្ដី អស់លោកចៅក្រម ត្រូវយកច្បាប់តុលាការមកអនុវត្តន៍ ។

ដើម្បីគាំទ្រនឹងការពារសេចក្ដីយុត្តិធម៌ កុំឲ្យល្អៀង គេបានបង្កើតក្រុមមួយផ្សេងទៀត ហៅថាក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ។ ក្រុមប្រឹក្សាជាន់ខ្ពស់នេះ មានលោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាអធិបតី ; សមាជិក ២ រូបបាត់តាំងដោយព្រះមហាក្សត្រិយ៍ ហើយនឹងសមាជិក ២

រូបទៀត ជ្រើសតាំងដោយវិជ្ជសភា ។

ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ មានភារៈ

មើលត្រួតត្រា កិច្ចអនុវត្តន៍ច្បាប់របស់ពួកចៅ

ក្រមឲ្យបានត្រឹមត្រូវ ។

ពាក្យពន្យល់.-

យុត្តិធម៌ = សេចក្តីទៀងត្រង់ ។

ព្រាហ្មណ្ណ = កាផ្សាព្រាហ្ម ។

វេជ្ជប្បវេណី = ប្រពៃណីសម្រាប់វេជ្ជ ។

អធិបតី = ធំបង្អស់ ។

អនុវត្តន៍ = ការធ្វើតាម ។

ពាក្យសួរ.-

១ – ដូចម្ដេច ហៅថាអំណាច ?

២ – អំណាចតុលាការ នៅត្រង់ណា ?

៣ – ច្បាប់តុលាការមាននៅគន្ថច្បាប់ណាខ្លះ ?

៤ – អ្នកណាគេទទួលបញ្ជាប់តុលាការ ?

៥ – តើក្រុមស្នងតែមួយឬច្រើន ដូចបញ្ជាប់តុលាការ - ឬទេ ?

៦ – ហេតុអ្វីបានគេបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ នៃតុលាការ ?

៧– អ្នកណាជាអធិបតីក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ?

## -- ព្រះមហាក្សត្រិយ៍ និងតុលាការជាន់ខ្ពស់ --

មេរៀន.-

ក្នុងអំណាចតុលាការ ព្រះមហាក្សត្រិយ៍ទ្រង់មានរាជសិទ្ធិ អាចដោះលែងមនុស្សទោស ឬ បន្ថយទោស ដល់អ្នកជាប់ទោសបានដែរ ។ រដ្ឋមន្ត្រីណាប្រព្រឹត្តខុសនឹងច្បាប់ ត្រូវរដ្ឋសភាប្តឹងទៅតុលាការជាន់ខ្ពស់ ឲ្យយកខ្លួនរដ្ឋមន្ត្រីនោះ ទៅជំនុំជំរះ ។

តុលាការជាន់ខ្ពស់ មានសមាជិក៥រូប គឺ ជ្រើសយកចៅក្រមជាន់ខ្ពស់ ២រូប, សមាជិករដ្ឋសភា១រូប, ក្រុមប្រឹក្សាព្រះរាជាណាចក្រ២រូប ។

ពាក្យពន្យល់.-

រាជសិទ្ធិ = អំណាចព្រះរាជា, អំណាចរបស់ស្តេច ។

រដ្ឋសភា = ទីប្រឹក្សាសម្រាប់រដ្ឋ ។

ពាក្យសួរ.—

១ – ព្រះមហាក្សត្រិយ៍ ទ្រង់មានរាជសិទ្ធិអ្វីទេ ក្នុងអំណាចតុលាការ ?

២ – អ្នកណាកាត់ក្ដី ដល់រូបវន្តបុគ្គលដែលប្រព្រឹត្ត ខុសនឹងច្បាប់ ។

៣ – តុលាការជាន់ខ្ពស់ មានសមាជិកប៉ុន្មានរូប ?

៤ – គេរើសយកសមាជិកនោះ ពីណាមក ?

## -ចៅក្រម និងព្រះរាជអាជ្ញា-

មេរៀន.-

ចៅក្រម មានពីរពួក ។ ចៅក្រមជំនុំជំរះកាត់ក្តីមួយពួក និងចៅក្រមចាំតែផ្សំសំណុំរឿងចោទមួយពួកទៀត ។ ចៅក្រមជំនុំជំរះកាត់ក្តី ហៅថា ចាងហ្វាងសាលា មានការៈកាត់ក្តីសម្រេចថា កូនក្តីណាខុស ណាត្រូវ ឬទទួលទោសប៉ុណ្ណេះ ប៉ុណ្ណោះ តាមច្បាប់តុលាការ ។

ឯចៅក្រមចាំផ្សំសំណុំរឿងចោទ ហៅថា ព្រះរាជអាជ្ញា ជាអ្នកតំណាងព្រះមហាក្សត្រិយ៍ ដើម្បីការពារប្រយោជន៍សង្គម ប្រឆាំងនឹងប្រយោជន៍បុគ្គលម្នាក់ៗ ដែលមានមេធាវី ជាអ្នកអះអាងការពារដែរ ។

ពាក្យសួរ.-

១ - តើក្រមមានប៉ុន្មានពួក ?

២ - ចាងហ្វាងសាលា មានការៈកិច្ចដូចម្ដេច ?

៣ - ព្រះរាជអាជ្ញា បំពេញមុខងារអ្វី ?

៤ - មេធាវី ជួយការពារអ្នកណា ?

## - សាលាលហុ -

មេរៀន.–

សាលាលហុ សម្រាប់ជំនុំជំរះបទលហុ គឺទោសល្មើសធ្វេសប្រហែសនឹងច្បាប់បញ្ញត្តិ ។ សាលាលហុមានអំណាចកាត់សេចក្ដី ធ្វើទោសដាក់គុកពី១ថ្ងៃទៅដល់៥ថ្ងៃយ៉ាងច្រើន (មានទុកផ្លូវឧទ្ធណ៍) បើពិន័យជាប្រាក់វិញពីត្រឹម១៥រៀលទៅដល់ ១៥០ រៀល (ឥតទុកផ្លូវឧទ្ធរណ៍ទេ) ប៉ុន្តែបើនឹងប្តឹងទៅសាលាវិនិច្ឆ័យបាន ។

សាលាលហុ មានចាងហ្វាង តែមួយទេ ដែលមានមុខការជំនុំជំរះ និងសំរេចកិច្ចទាំង-ឡាយជាផ្លូវការ ។ មានក្រឡាបញ្ជីម្នាក់ ជួយកិច្ចការផ្សេងៗ ព្រមទាំងអមចាងហ្វាង ក្នុងការជំនុំជំរះ ។ ក្នុងប្រទេសខ្មែរយើង មានសាលា

លហុតែ ២ ទេ គឺមាននៅក្រុងភ្នំពេញមួយ ដែលយើងធ្លាប់ហៅថាសាលាលុហុន ហើយទីពីរមាននៅក្នុងខេត្តបាត់ដំបង ១ ទៀត ។

ចំណែកឯខេត្តនានាវិញ គេធ្វើសាលាលហុ នឹងសាលាដំបូង ។ ចាងហ្វាងសាលាដំបូង ក៏មានមុខងារ ជាចាងហ្វាងសាលាលហុដែរ ។

ពាក្យសួរ.–

១ – សាលាលហុ ជំនុំជំរះបទអ្វី ?

២ – សាលានេះ មានអំណាចកាត់ទោសដាក់គុក ពីប៉ុន្មានថ្ងៃ ទៅដល់ប៉ុន្មានថ្ងៃ ?

៣ – បើពិន័យជាប្រាក់វិញ ពីប៉ុន្មានរៀល ទៅដល់ប៉ុន្មានរៀល ?

៤ – ក្នុងសាលាលហុ មានចាងហ្វាងប៉ុន្មាននាក់ ?

៥ – ស្រុកខ្មែរ មានសាលាលហុប៉ុន្មាន ?

៦ – សាលាលហុនៅភ្នំពេញ មានឈ្មោះអ្វី ជាពិសេស ?

## – សាលាដំបូង –

មេរៀន .–

សាលាដំបូងតាំងនៅគ្រប់ទីរួមខេត្តទាំងអស់ នៃកម្ពុជរដ្ឋ ។

នៅសាលាដំបូងនីមួយ ៗ មានចៅហ្វាយសាលា, ព្រះរាជអាជ្ញា, សុភាចារបុរស, ក្រឡាបញ្ជី និង សមុហបញ្ជី ។

សាលាដំបូង សម្រាប់ជំនុំជំរះកាត់សេចក្ដីរឿងអាជ្ញាគតិ បានត្រឹមតែបទមជ្ឈិមទោ គឺទោ-:ទោសដាក់គុក ពី ៦ ថ្ងៃ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ ពីត្រឹម ១៥១ រៀល ទៅដល់ ៤០.០០០ រៀល

ពាក្យពន្យល់ .-

ចៅហ្វាយសាលា = ចៅក្រមជំនុំជំរះកាត់ក្ដី ។

ព្រះរាជអាជ្ញា = ទៅក្រមផ្សំសំណុំរឿងទោទ ជាអ្នក

តំណាងព្រះរាជា ។

សុភាចារបុរស = ទៅក្រមស៊ើបសួរ ។

ពាក្យសួរ .-

១ - ក្នុងទីប្រជុំខេត្តរបស់អ្នក មានសាលាជំនុំជំរះ

កាត់ក្ដីឬទេ ? គេហៅថាសាលាអ្វី ?

២ - ក្នុងសាលាដំបូងមានចៅក្រមប៉ុន្មាននាក់ ?

៣ - សាលាដំបូង កាត់សេចក្ដីរឿងអាជ្ញាគតិ បាន

ត្រឹមណា ?

៤ - សាលានេះ មានអំណាចដាក់ទោសមនុស្សជាប់

គុកប៉ុន្មានឆ្នាំយ៉ាងច្រើន ? បើពិន័យជាប្រាក់ ពី-

ត្រឹមប៉ុន្មានរៀលទៅដល់ប៉ុន្មានរៀល ?

# - សាលាក្រុមចោទ -

មេរៀន .-

សាលាក្រុមចោទ តាំងនៅក្រុងភ្នំពេញ សម្រាប់ពិនិត្យមើលពាក្យចោទផ្សេងៗ ដែលគូក្តី មិនសុខចិត្តនឹងការជំនុំជំរះនៅសាលាដំបូងនា - នា ៗ លុះបានពិចារណាមើលរឿងទាំងនោះ ត្រឹមត្រូវហើយ ឬមួយនៅមានចន្លោះកិច្ចម្យ៉ាង ៗ ពុំបានពោលសេចក្តីបរិបូណ៌ ក៏ធ្វើតតមានតាមហេតុពិនិត្យនោះជូនទៅសាលាឧទ្ធរណ៍ជំនុំជំរះ ៗ សាលាក្រុមចោទ ជាសាលាជំនួយនៃសាលាឧទ្ធរណ៍ ៗ

ពាក្យពន្យល់ .-

ពិចារណា = ពិនិត្យមើលយ៉ាងម៉ត់ចត់ ៗ

ពតិមាន = ដំណឹង, សេចក្តីឲ្យការម្យ៉ាង ៗ ៗ

ពាក្យសួរ –

១ – បើគូក្តីមិនសុខចិត្តនឹងសេចក្តីសំរេចរបស់សាលា-ដំបូង ត្រូវបញ្ជូនសំណុំរឿងទៅឯសាលាណាទៀត ?

២– សាលាក្រុមចោទមានភារៈបំពេញមុខងារដូចម្តេច ?

៣– សាលាក្រុមចោទ មានតាំងនៅឯទីណា ?

# –សាលាឧទ្ធរណ៍–

មេរៀន. –

សាលាឧទ្ធរណ៍ មានតែមួយទេ តាំងនៅក្រុងភ្នំពេញ សម្រាប់ពិភាក្សា កាត់សេចក្ដីសាជាថ្មី ដែលគូក្ដីមិនសុខចិត្ត នឹងសាលាលហុសាលាដំបូង ដែលជំនុំជំរះកាត់សេចក្ដី បើគេប្ដឹងឧទ្ធរណ៍ អំពីបទលហុក្ដី បទមជ្ឈិមក្ដី

ពាក្យពន្យល់.–

ពិភាក្សា = ប្រឹក្សាគ្នា ។

បទលហុ = បទស្រាលបំផុត ។

បទមជ្ឈិម = បទកណ្ដាល ។

ពាក្យសួរ. –

១ – សាលាឧទ្ធរណ៍បំពេញមុខងារដូចម្ដេច ?

២ – ស្រុកខ្មែរយើងមានសាលាឧទ្ធរណ៍ប៉ុន្មាន ? តាំងនៅឯណា ?

## – សាលាឧក្រិដ្ឋ –

មេរៀន. –

សាលាឧក្រិដ្ឋ សម្រាប់ជំនុំជំរះទោសធ្ងន់ដែលចូលជាបទឧក្រិដ្ឋ តាំងពីទោស ៥ ឆ្នាំទៅដល់ទោសអស់ជីវិត ឬត្រូវពិឃាតជីវិតជន៍ ។ បើមិនសុខចិត្តនឹងសាលក្រម សាលាឧក្រិដ្ឋទេត្រូវប្តឹងទៅសាលាវិនិច្ឆ័យជាសំរេច ។

ពាក្យពន្យល់. –

ពិឃាត = ប្រហារជីវិត, សម្លាប់ ។

ទោសឧក្រិដ្ឋ ដូចជាៈទោសលួចសម្លាប់គេជាដើម ។

ពាក្យសួរ.–

១– សាលាអ្វី ដែលមានអំណាចធំជាងសាលាសាឧទ្ធរណ៍ ?

២— ស្រុកខ្មែរមានសាលាឧក្រិដ្ឋប៉ុន្មាន ?

៣— សាលាឧក្រិដ្ឋ កាត់ទោសដូចម្ដេច ?

៤— បើគេមិនសុខចិត្តទឹងសាលក្រមរបស់សាលា

ឧក្រិដ្ឋ តើត្រូវប្ដឹងទៅសាលាណាទៀត ?

# -សាលាវិនិច្ឆ័យ-

មេរៀន.-

សាលាវិនិច្ឆ័យ មានតែមួយគត់នៅក្រុងភ្នំពេញ ។ គឺជាសាលាធំបំផុតសម្រាប់ពិនិត្យរឿងហេតុ នឹងជំនុំជំរះសាឡើងវិញ នូវក្តីណាដែលគូវិវាទប្តឹងសាទុក្ខមិនសុខចិត្តនឹងសាលក្រម, សាលាលហុ, សាលាដំបូង, សាលាឧទ្ធរណ៍, សាលាឧក្រិដ្ឋ ។ បើពិភាក្សាទៅឃើញថាខុសនឹងច្បាប់ ក៏ជំនុំជំរះកាត់សាជាថ្មីម្តងទៀតឲ្យបានត្រឹមត្រូវ បើឃើញថាបានជំនុំជំរះសុបតែត្រឹមត្រូវហើយ ក៏បដិសេធពាក្យបណ្តឹងសាទុក្ខចេញ ។

សាលាជំនុំជំរះក្តីក្នុងប្រទេសខ្មែរ ផុតអស់ត្រឹមសាលាវិនិច្ឆ័យនេះហើយ ។

ពាក្យពន្យល់ .–

ពិនិត្យសាជាថ្មី – មើលឡើងទៀតដោយម៉ត់ចត់ ។

បដិសេធ – លុបចោល, លែងចោល ។

ពាក្យសួរ –

១ – សាលាជំនុំជំរះក្តី ធំបំផុតនៅស្រុកខ្មែរ គឺសាលាណា ?

២ – សាលាវិនិច្ឆ័យតាំងនៅឯណា ?

៣ – សាលានេះបំពេញមុខងារដូចម្តេច ?

៤ – សាលានេះអាចយករដ្ឋមន្ត្រីណាមួយ ដែលប្រព្រឹត្តខុសនឹងច្បាប់ ទៅជំនុំជំរះកាត់ទោសបានឬទេ ?

៥ – ក្រុមតុលាការ អាចយកអំណាចទៅជំនុំជំរះកាត់ក្តី ដល់អ្នកតំណាងរាស្ត្រ ដែលនៅជាសមាជិកភាពបាន ឬទេ ? ដោយហេតុអ្វី ?

★ ★

# – បទប្រព្រឹត្ត ដែលមានទោសក្នុងច្បាប់ –

មេរៀន

បទប្រព្រឹត្ត ដែលមានទោសក្នុងច្បាប់បាន

ចែកជា ៣ សណ្ឋាន ៖

១ – បទឧក្រិដ្ឋ

២ – បទមជ្ឈិម

៣ – បទលហុ

ក – បទឧក្រិដ្ឋមាន៣យ៉ាង ៖

១ – បទឧក្រិដ្ឋថ្នាក់ទី ៣ ត្រូវប្រហារជីវិត ។

២ – បទឧក្រិដ្ឋថ្នាក់ទី ២ ត្រូវដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់អស់មួយជីវិត ។

៣ – បទឧក្រិដ្ឋថ្នាក់ទី ១ ត្រូវដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់ មានកំណត់វេលា ។

## ខ-បទមជ្ឈិមមាន ៣ យ៉ាង

១ – បទមជ្ឈិមថ្នាក់ទី ៣ ត្រូវដាក់គុកពី ១ ឆ្នាំទៅដល់ ៥ ឆ្នាំ ហើយពិន័យពី ៤.០០១ រៀលទៅដល់ ៤០.០០០ រៀល ។

២– បទមជ្ឈិមថ្នាក់ទី ២ ត្រូវដាក់គុកពី១ខែទៅដល់១ ឆ្នាំ ហើយពិន័យជាប្រាក់ ពី១.២០១ រៀល ទៅដល់៤.០០០ រៀល ។

៣ – បទមជ្ឈិមថ្នាក់ទី ១ ត្រូវដាក់គុកពី៦ថ្ងៃ ទៅដល់ ១ខែ ហើយពិន័យពី ១៥១ រៀល ទៅដល់ ១.២០០ រៀល ។

កត់ចំណាំ– ទោសបទមជ្ឈិមទាំង៣ថ្នាក់នេះ គ្រាន់តែដាក់គុក ឬគ្រាន់តែពិន័យក៏បាន ។

## គ-បទលហុ

បទលហុ ជាបទល្មើស ដែលត្រូវផ្តន្ទាទោស